International
Labour
Organization

better
factories
Cambodia

# សេចក្តីជូនដំណឹង

## <u>លិខិតអញ្ជើញចូលរួម</u>

## ពិធីផ្សព្វផ្សាយគំរោងកិច្ចគាំពារសង្គម និងយ៉េនឌ័រ របស់កម្មវិធី គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការពលកម្មអន្តរជាតិ (ILO)

**កាលបរិច្ឆេទ:** ថ្ងៃ ច័ន្ទ ទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០

**វេលាម៉ោង** : ២ រសៀល

**ទីកន្លែង** : សណ្ឋាគារ កាំបូឌីយ៉ាណា

**កម្មវត្ថុ** : នៅឯពិធីផ្សព្វផ្សាយនៃគំរោងកិច្ចគាំពារសង្គម និងយ៉េនឌ័រនេះ **ឯកឧត្តម វេជ្ជបណ្ឌិត ហុយ ហានសុង** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **លោកជំទាវ ច័ន្ទ សូរីយ៉** រដ្ឋលេខាក្រសួងកិច្ចការនារី និង**ឯកឧត្តម Mariano Alonso Buron** ឯកអគ្គរដ្ឋទូតប្រទេសអេស្ប៉ាញប្រចាំនៅប្រទេសកម្ពុជា នឹងថ្លែងសន្ទរកថាដើម្បីបើកឱ្យដំណើរការជាផ្លូវការនូវគំរោងនេះ។

នារសៀលនោះផងដែរ ក៏នឹងមានកិច្ចពិភាក្សាលើកិច្ចគាំពារសង្គមក្នុងឧស្សាហកម្មកាត់ដេរផងដែរ។ អ្នកចូលរួមកិច្ចពិភាក្សានោះរួមមាន លោកស្រី Aurore Lambert ប្រធានគំរោង GRET/HIP លោក Ken Loo អគ្គលេខាធិការនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) លោកស្រី ម៉ម ញឹម ប្រធានសម្ព័ន្ធសហព័ន្ធសហជីពការងារកម្ពុជា និងលោកស្រី Minna Barling ជំនួយការកម្មវិធីអន្តរជាតិ នៃអង្គការ Marie Stopes International Cambodia។

គំរោងកិច្ចគាំពារសង្គម និងយេនឌ័រ របស់កម្មវិធី*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដែលអនុវត្តន៍ដោយ អង្គការពលកម្មអន្តរជាតិ (ILO) មានគោលបំណងដើម្បីធ្វើឱ្យប្រសើរនូវសុខុមាលភាព និងសុខភាពរបស់កម្មការិនី ពង្រឹងនូវគោលនយោបាយឆ្លើយតបនឹងបញ្ហាយេនឌ័រនៅកន្លែងធ្វើការ ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅកន្លែងធ្វើការ និងដើម្បីលើកកម្ពស់ការណែនាំពីការងារមុនចាប់ផ្តើមធ្វើការ និងឱកាសការងារបន្ទាប់ពីបញ្ចប់ការងារក្នុងរោងចក្រ។ គំរោងនេះត្រូវបានផ្តល់មូលនិធិដោយទីភ្នាក់ងារអភិវឌ្ឍន៍របស់ប្រទេសអេស្ប៉ាញ សម្រាប់រយៈពេលពីរឆ្នាំ ពីឆ្នាំ ២០១០ ដល់ ២០១១។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក

លោក ប៊ុន យិញ
មន្ត្រីទំនាក់ទំនងព័ត៌មាន
ទូរស័ព្ទ : ០១២ ៩០២ ៩៩០
អ៊ីម៉េល : ying@ilo.org

លោកស្រី នូ ភារី
មន្ត្រីកម្មវិធីថ្នាក់ជាតិ
ទូរស័ព្ទ : ០១២ ២២៥ ៦៥៦
អ៊ីម៉េល : pheary@ilo.org